Joint Climate Change Initiative
JCCI

#១១
ខែឧសភា ឆ្នាំ២០១៣
តើមានអ្វីថ្មី? ទំព័រ ១
សេចក្តីសង្ខេបគម្រោងជេ.ស៊ី.ស៊ី.អាយ ឆ្នាំ២០១២ ទំព័រ ២
សៀវភៅផែនទីប្រទេសកម្ពុជា ទំព័រ ៣
សាច់រឿងទទួលបានពីអង្គការដៃគូ ទំព័រ ៤
កាលបរិច្ឆេទអំពីការប្រែប្រួលអាកាសធាតុសំខាន់ៗ ទំព័រ ៦
FORUM SYD | CORD | DAN CHURCH AID/CHRISTIAN

ទាក់ទងលោក Johannes Nilsson ជាមន្ត្រីផ្នែកទំនាក់ទំនង
johannes.nilsson@forumsyd.org

## ជូនចំពោះដៃគូគម្រោងអាកាសធាតុទាំងអស់

សូមស្វាគមន៍ចំពោះការចេញផ្សាយព្រឹត្តិបត្រព័ត៌មានចុងក្រោយបង្អស់អំពីគម្រោងជេ.ស៊ី.ស៊ី.អាយ ដែលក្នុងនោះ យើងធ្វើការចែករំលែកបទពិសោធន៍ និង សាច់រឿងមួយចំនួន ដែលទទួលបានពីគំនិតផ្តួចផ្តើមនេះ ព្រមទាំងសកម្មភាពនានារបស់អង្គការដៃគូទាក់ទងនឹងប្រទេសកម្ពុជា និង កម្មវិធីចុះតាមតំបន់។ ប្រសិនបើលោកអ្នកចង់ផ្តល់មតិយោបល់ផ្សេងៗទៅលើខ្លឹមសារ ឬ មានបំណងចង់ចូលរួមចំណែកក្នុងរបាយការណ៍ផ្លូវការណ៍នេះ លោកអ្នកអាចទាក់ទងបានតាមរយៈអ៊ីម៉េលខាងលើនេះ។

## តើមានអ្វីថ្មី?

### តំបន់គំរូក្នុងគម្រោងជេ.ស៊ី.ស៊ី.អាយ

នៅក្នុងឆ្នាំ ២០១៣ គម្រោងជេ.ស៊ី.ស៊ី.អាយ គាំទ្រដល់អង្គការដៃគូចំនួន ប្រាំ ក្នុងចំណោមអង្គការដៃគូដំបូងបង្អស់ តាមរយៈវិធីសាស្រ្តជាក់លាក់ជាងមុន ដោយផ្តោតជាសំខាន់ទៅលើការបង្កើតតំបន់គំរូសម្រាប់ការបន្សាំតាមសហគមន៍។ អង្គការដៃគូទាំងប្រាំ ដែលកំពុងតែអនុវត្តតំបន់គំរូនៅក្នុងឆ្នាំនេះ រួមមាន អង្គការសេដាក (ក្នុងខេត្តកំពង់ឆ្នាំង) ដែលផ្តោតសំខាន់លើផ្នែកកសិកម្ម អង្គការឌី.ភី.អេ (ក្នុងខេត្តរតនគិរី) និង អង្គការអ៊ិម.វី.អាយ (ក្នុងខេត្តកំពង់ឆ្នាំង) ដែលផ្តោតសំខាន់លើជនជាតិដើមភាគតិច អង្គការហ្សេក (ក្នុងខេត្តសៀមរាប) ដែលធ្វើការជាមួយនឹងសហគមន៍នេសាទ និង អង្គការខេ. វ៉ាយ.អេស.ឌី (ក្នុងខេត្តកំពង់ស្ពឺ) ដែលធ្វើការមួយនឹងយុវជន។ តាមរយៈក្រុម និង គម្រោងគោលដៅផ្សេងៗគ្នាដែលបានពង្រីកពេញផ្ទៃប្រទេសកម្ពុជានេះ គម្រោងទាំងអស់នោះ ផ្តោតទៅលើការពង្រឹងសមត្ថភាពរបស់សហគមន៍មូលដ្ឋាន និង សមត្ថភាពរបស់ភាគីពាក់ព័ន្ធទាំងឡាយ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការលើកកម្ពស់ការប្រើប្រាស់ និង ការគ្រប់គ្រងធនធានធម្មជាតិឲ្យកាន់តែមាននិរន្តរភាពថែមទៀត។

### ការពិគ្រោះមតិអំពីការប្រែប្រួលអាកាសធាតុ

ក្នុងឆ្នាំ២០១២ កន្លងទៅនេះ គម្រោងជេ.ស៊ី.ស៊ី.អាយ បានរៀបចំសិក្ខាសាលាពិគ្រោះមតិស្តីពីការប្រែប្រួលអាកាសធាតុ រួមគ្នាជាមួយនឹង អង្គការសង្គ្រោះសត្វព្រៃកម្ពុជា (អេស.ស៊ី.ដាប៊ែលយូ) និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (អ៊ិន.ជី.អូ.ហ្វ៊ុម)។ សិក្ខាសាលានេះបាននាំមកនូវលទ្ធផលជាទស្សនាទានចំនួន បី សម្រាប់ការងារជាបន្តទៀត រួមមាន ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការធ្វើផែនការយុទ្ធសាស្រ្តស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ការពិនិត្យតាមដានមើលហិរញ្ញវត្ថុសម្រាប់ការងារអាកាសធាតុ និង យន្តការផ្តល់ព័ត៌មានអំពីអាកាសធាតុ។ បន្ទាប់ពីបានប្រមូលផ្តុំរាល់មតិយោបល់ទាំងអស់ពីសិក្ខាសាលានេះ អ៊ិន.ជី.អូ ហ្វ៊ុម បណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (ស៊ី.ស៊ី.ស៊ី.អ៊ិន) និង មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ី.ស៊ី.អាយ.អ៊ិម) បាននឹងកំពុងដឹកនាំឆ្ពោះទៅសម្រេចលទ្ធផលទាំងនេះក្រោមជំនួយហិរញ្ញវត្ថុពីគម្រោងជេ.ស៊ី.ស៊ី.អាយ។

## គម្រោងជេ.ស៊ី.ស៊ី.អាយ ចែករំលែកបទពិសោធន៍ និង ឯកសារបោះពុម្ពផ្សាយនៅវេទិកាអាស៊ី-ប៉ាស៊ីហ្វិកលើកទីបីស្តីពីការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

វេទិកាអាស៊ី-ប៉ាស៊ីហ្វិកលើកទីបី ស្តីពី ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលរៀបចំឡើងនៅក្នុងទីក្រុងអ៊ីនឈុន (Incheon) ក្នុងឆ្នាំ២០១៣នេះ ប្រទេសកូរ៉េខាងត្បូងបានផ្តល់ទីកន្លែងសម្រាប់ជួបប្រជុំ ទាក់ទងគ្នា និង ចែករំលែកព័ត៌មាន និង បទពិសោធន៍ ដែលទទួលបានពីកម្មវិធី និង សកម្មភាពខុសៗគ្នានៅក្នុងបណ្តាប្រទេសអាស៊ី-ប៉ាស៊ីហ្វិក ហើយវេទិកានេះត្រូវបានរៀបចំឡើងដោយផ្តោតជុំវិញទិដ្ឋភាពចំនួន បួន គឺ យុទ្ធសាស្ត្របន្សុាំ ក្រុមដែលប្រឈមគ្រោះថ្នាក់ និង ដែលមិនទទួលបានការយកចិត្តទុកដាក់ការបន្សុាំតាមវិស័យ និង តាមប្រព័ន្ធ និង ការគ្រប់គ្រងចំណេះដឹងសម្រាប់ការបន្សុាំ។

គម្រោងជេ.ស៊ី.ស៊ី.អាយ បានចូលរួមក្នុងវេទិកានេះ ដើម្បីចែករំលែកបទពិសោធន៍នានា ដែលទទួលបានពីប្រទេសកម្ពុជា ហើយក៏បានចែកចាយសៀវភៅសិក្សាដែលទើបនឹងបានបោះពុម្ពរួចផងដែរ។ អង្គការហ្វ៊ែម ស៊ីដ ឌី.ស៊ី.អេ/ស៊ី.អេ ស៊ី.ស៊ី.ស៊ី.អ៊ិន អ៊ិន.ជី.អូ ហ្វ៊ែម និង អង្គការខេ.វ៉ាយ.អេស.ឌី បានធ្វើជាតំណាងរបស់គម្រោងជេ.ស៊ី.ស៊ី.អាយ នៅក្នុងវេទិកាទាំងមូល។ **ហេង សុគន្ធា** (Heng Sok Kunthea) បានបង្ហាញពីការងាររបស់ខ្លួនជាមួយនឹងយុវជន និង ការប្រែប្រួលអាកាសធាតុនៅក្នុងក្រុមពិភាក្សាអំពី *ទំនាក់ទំនងយេនឌ័រ យុវជន និង ការបន្សុាំ* នៅក្នុងថ្ងៃទីបី ដោយទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួម។

## ឯកសារបោះពុម្ពថ្មីអំពីគម្រោងជេ.ស៊ី.ស៊ី.អាយ មានសម្រាប់ចែកជូន!

អង្គការភ្លែន អង្គការទស្សនៈពិភពលោក អង្គការការីតាសកម្ពុជា និង គម្រោងជេ.ស៊ី.ស៊ី.អាយ បានរួមគ្នាបង្កើត "សៀវភៅណែនាំអំពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលជាសៀវភៅសិក្សាមួយសម្រាប់អង្គការ និង ស្ថាប័ននៅក្នុងប្រទេសកម្ពុជា (មានសរសេរជាភាសាខ្មែរ និង ភាសាអង់គ្លេស)" និង "សៀវភៅណែនាំអំពីការអនុវត្តល្អៗ" (សរសេរជាភាសាអង់គ្លេស និង ភាសាខ្មែរ ដែលនឹងមាននាប់ៗនេះ) ដោយរួមបញ្ចូលនូវការរៀនសូត្រដែលទទួលបានពីគម្រោងជេ.ស៊ី.ស៊ី.អាយ និង អង្គការដៃគូ។ ឯកសារទាំងអស់នេះ នឹងមានផ្តល់ជូនទៅតាមការស្នើសុំ។ សូមទាក់ទងទៅលោក ណុប ប៉ូលីន ជាមន្ត្រីតស៊ូមតិក្នុងគម្រោងជេ.ស៊ី.ស៊ី.អាយ ធ្វើការនៅអង្គការឌី.ស៊ី.អេ/ស៊ី.អេ សម្រាប់ព័ត៌មានបន្ថែម។

## សេចក្តីសង្ខេបកាលពីឆ្នាំ ២០១២

ក្នុងឆ្នាំ២០១២កន្លងទៅ អង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ បានចុះជួបជាមួយស្ត្រី និង បុរសប្រហែល ១៧.០០០នាក់ ដើម្បីធ្វើការកសាងសមត្ថភាព ធ្វើការតស៊ូមតិ និង ធ្វើសកម្មភាពផ្សេងៗនៅតាមសហគមន៍ទូទាំងប្រទេស។ មិនតែប៉ុណ្ណោះ បុគ្គលិកក្នុងមូលដ្ឋានចំនួន ៤៣០នាក់ បានចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាល និង កសាងសមត្ថភាព ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់អំពីការប្រែប្រួលអាកាសធាតុ និង វិធីសាស្ត្រដែលមានការចូលរួម ព្រមគ្នាជាមួយនឹងទីប្រឹក្សា និង អ្នករួមការងារក្នុងគម្រោងជេ.ស៊ី.ស៊ី.អាយ មកពីអង្គការជាច្រើនទូទាំងប្រទេស និង ពីអាស៊ីអាគ្នេយ៍ផងដែរ។

សម្រាប់អង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ ចំនួនប្រាំ (អូ.ឌី.អូ.វី ខេនឌុ អេហ្វ.អេ.ស៊ី.ធី ខេ.វ៉ាយ.អេស.ឌី និង ជី.អេ.ឌី/ស៊ី) ការដាំកូនឈើ បានក្លាយទៅជាចំណុចស្នូលមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ការដាំឈើហូបផ្លែ ឈើសម្រាប់ធ្វើអុស ឈើប្រណីត និង ព្រៃកោងកាងបានកើតឡើង ដោយក្នុងនោះអង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយបានដាំកូនឈើសរុបចំនួន ២៥.៨៦២ ដើមនៅក្នុងឆ្នាំ២០១២។

កិច្ចខិតខំប្រឹងប្រែងផ្សេងទៀតនៅក្នុងឆ្នាំ២០១២ គឺការដំឡើងឡជីវៈឧស្ម័ននៅតាមសហគមន៍ជនបទ។ អង្គការដៃគូឈ្មោះ អូ.ឌី.អូ.វី បានដំឡើងប្រព័ន្ធនេះចំនួន ៧ នៅក្នុងតំបន់គោលដៅរបស់ខ្លួន ដែលបានធ្វើឲ្យពលរដ្ឋមួយភាគធំក្នុងតំបន់គោលដៅនោះ ឈប់ដុតចំបើងដូចមុនទៀត។ ក្រៅពីកាត់បន្ថយការបំភាយកាបូន ប្រតិបត្តិការនេះ បានជួយកាត់បន្ថយការពឹងផ្អែករបស់ពលរដ្ឋមូលដ្ឋានទៅលើឈើសម្រាប់ធ្វើអុសដុត និង បានកាត់បន្ថយសម្ពាធទៅលើព្រៃក្នុងមូលដ្ឋាន។ អង្គការជីវិតថ្លៃថ្នូរ បានដំឡើងប្រព័ន្ធនេះចំនួន ១០២ កន្លែង ដែលបានជួយសម្រាលបន្ទុករបស់ស្ត្រីក្នុងការស្វែងរកអុសសម្រាប់ការចម្អិនអាហារប្រចាំថ្ងៃ និង បានចំណាយពេលលាងសម្អាតចានឆ្នាំងតិចជាងការដែលដុតធ្យូង ជួយឲ្យពួកគាត់សន្សំពេលបានច្រើនសម្រាប់ធ្វើការងារផ្ទះផ្សេងទៀត។ នៅតាមតំបន់គោលដៅទាំងអស់ ដែលបានដំឡើងប្រព័ន្ធជីវៈឧស្ម័ននេះ មានការកត់សម្គាល់ឃើញថា ក្រុមគ្រួសារមានសុខភាពល្អជាងមុន ដោយសារគ្មានផ្សែង ហើយបរិស្ថានមានសន្តិសុខជាងមុន ពីព្រោះគ្រួសារទាំងឡាយលែងរស់នៅក្រោមផ្សែងធ្យូង ឬ លែងមានការលំបាកដោយសារភាពងងឹតទៀតហើយ ដោយសារថាប្រភពថាមពលថ្មីនេះធានាបាននូវប្រភពភ្លើងបំភ្លឺចាំបាច់ក្នុងពេលយប់។

ចំណុចរឹជ្ជមានមួយផ្សេងទៀត ដែលផុសចេញពីការងារដែលអង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ បានធ្វើនៅក្នុងឆ្នាំ២០១២នោះ គឺទាក់ទងទៅនឹងការយល់ឃើញរបស់ប្រជាកសិករចំពោះគំនិតផ្តួចផ្តើមថ្មីៗផ្នែកកសិកម្ម។ នៅក្នុងតំបន់គោលដៅរបស់អង្គការបន្ទាយស្រី គម្រោងជេ.ស៊ី.ស៊ី.អាយ បានរកឃើញមានគម្រោងមួយដែលបានធ្វើឱ្យអ្នកភូមិលែងចង់ទិញបន្លែ ផ្លែឈើ ដែលដាំដោយប្រើប្រាស់ជីគីមីតទៅទៀត។ គម្រោងនេះបានលើកទឹកចិត្តកសិករឱ្យដាំដំណាំតាមបែបសរីរាង្គ ហើយទន្ទឹមគ្នានោះពួកគាត់អាចបន្ថែមតម្លៃបានរហូតដល់ ២៥% បន្ថែមទៀតសម្រាប់កសិផលរបស់ពួកគាត់។ ស្រដៀងគ្នានេះដែរ នៅក្នុងតំបន់គោលដៅរបស់អង្គការឌី.ភី.អេ អ្នកភូមិដីឡូត៍ និង ភូមិលំផាត់ រកបានប្រាក់ចំណូលបន្ថែមរហូតដល់ ១.០៨៩.០០០រៀល ពីការដាំបន្លែនៅក្នុងរដូវវស្សា។

Joint Climate Change Initiative

សហគមន៍ និង អង្គការក្នុងប្រទេសកម្ពុជា កំពុងរៀនសូត្រ និង ធ្វើការជាមួយគ្នាដើម្បីកសាងសមត្ថភាព និង ភាពស៊ាំ។

## សៀវភៅផែនទីប្រទេសកម្ពុជា

ក្នុងពេលកន្លងទៅថ្មីៗនេះ គម្រោងជេ.ស៊ី.ស៊ី.អាយ និង អង្គការស៊ី.ស៊ី.ស៊ី.អ៊ិន បានចូលរួមក្នុងគម្រោងសៀវភៅផែនទីប្រទេសកម្ពុជារបស់អង្គការសង្គ្រោះសត្វព្រៃកម្ពុជា (អេស.ស៊ី.ដាប៊ែលយូ) ដើម្បីសរសេរធម្មនុញ្ញអាកាសធាតុសម្រាប់បោះពុម្ពផ្សាយថ្មីបន្ថែមទៀត។ កំណែថ្មីនៃសៀវភៅផែនទីនេះនឹងផ្អែកទៅលើសៀវភៅមួយដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០០៦ ក៏ប៉ុន្តែមានបន្ថែមជំពូកមួយចំនួនដែលនិយាយអំពីជីវៈចម្រុះ ទេសចរណ៍ និង ទិដ្ឋភាពនយោបាយជាដើម។ សៀវភៅផែនទីនេះ មានគោលបំណងបម្រើជាមូលដ្ឋានចំណេះដឹងដែលមានគុណភាពមួយសម្រាប់សិស្ស/និស្សិត អ្នកអភិវឌ្ឍ និង អ្នកធ្វើសេចក្តីសម្រេចទាំងឡាយ ដោយបានលើកឡើងពីទំនាក់ទំនងរវាងធនធានធម្មជាតិ និង ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។

សៀវភៅផែនទីប្រទេសកម្ពុជានេះ គ្រោងនឹងចេញនៅចុងឆ្នាំ២០១៣នេះ ដែលនឹងចេញផ្សាយទាំងជាសៀវភៅ និង ជា Soft Copy ដោយមានទិន្នន័យបើកចំហសម្រាប់ធ្វើការវិភាគផងដែរ។

**សូមទាក់ទងអ្នកនាង** Rebeca SANDOVAL

នៅអង្គការអេស.ស៊ី.ដាប៊ែលយូ



Photo: Nicolas Axelrod



Photos: FACT

# ភ្លើងឆេះព្រៃបំផ្លិចបំផ្លាញព្រៃលិចទឹក ដែលបានគំរាមកំហែងដល់ទីជម្រកមច្ឆាក្នុងមូលដ្ឋាន និង ការប្រកបរបរចិញ្ចឹមជីវិត

ក្នុងរយៈពេល ៨ថ្ងៃ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែមេសា ភ្លើងឆេះព្រៃមួយបានបំផ្លិចបំផ្លាញព្រៃលើផ្ទៃដីទំហំ ១១ហិកតា នៅក្នុងឃុំកំពង់ភ្លុក ខេត្តសៀមរាប ស្ថិតក្នុងតំបន់គោលដៅរបស់អង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ ឈ្មោះ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (អេហ្វ.អេ.ស៊ី.ធី)។ ព្រៃលិចទឹកស្ថិតនៅជុំវិញឃុំកំពង់ភ្លុកនេះ មិនត្រឹមតែជាតំបន់អេកូទេសចរណ៍ដ៏ពេញនិយមប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាទីជម្រកដ៏សំខាន់សម្រាប់មច្ឆាផងដែរ ដែលជាធនធានដ៏សំខាន់បំផុតសម្រាប់ការរស់រានរបស់មនុស្សយ៉ាងច្រើន។ អគ្គិភ័យនេះបានកើតឡើងបន្ទាប់ពីមានមនុស្ស ៣-៤នាក់ ដែលដើររកអុសបំពេញតម្រូវការប្រចាំថ្ងៃនោះ បានទុកភ្លើងដែលដុតចម្អិនអាហារចោលដោយមិនបានពន្លត់។ តាមរយៈកិច្ចសហការល្អរវាងអង្គការហ្វេក អាជ្ញាធរភូមិ ស្រុក កងកម្លាំងអាវុធហត្ថ មន្ទីរជលផល អង្គការមូលដ្ឋាន និង ពលរដ្ឋក្នុងមូលដ្ឋាន អគ្គិភ័យនោះទីបំផុតគ្រប់គ្រងបានបន្ទាប់ពីឆេះអស់រយៈពេល ៨ថ្ងៃ។

ឥទ្ធិពលពីអគ្គិភ័យនេះ រួមមានការបាត់បង់ទីជម្រកមច្ឆាចំនួន ១១ហិកតា សម្រាប់រដូវវស្សាក្នុងឆ្នាំ២០១៣ ហើយទំនងជាឈានទៅដល់ការធ្លាក់ចុះផ្នែកទេសចរណ៍នៅក្នុងតំបន់ផងដែរ។ សម្រាប់ឥទ្ធិពលភ្លាមៗ អគ្គិភ័យបានធ្វើឲ្យប៉ះពាល់ដល់សហគមន៍ទាំងឡាយដែលនៅជាប់នោះ តាមរយៈការបាត់បង់មុខរបរចិញ្ចឹមជីវិត និង ការភ័យខ្លាចក្រែងអគ្គិភ័យនោះបន្តរាលដាលដល់ភូមិ។ នៅក្នុងឃុំកំពង់ភ្លុក អាជ្ញាធរ និង សហគមន៍ នឹងបន្តធ្វើការពង្រឹងប្រព័ន្ធព្រមានជាមុន និង ការគ្រប់គ្រងគ្រោះមហន្តរាយ ហើយធានាឲ្យមានរថយន្តពន្លត់អគ្គិភ័យត្រៀមទុកបានល្អប្រសើរជាងមុន។ ហានិភ័យជាក់ស្តែងនៃអគ្គិភ័យ ទង្វើរបស់មនុស្ស ឬ ធាតុអាកាស និង អាកាសធាតុ គឺជាការជំរុញដ៏ខ្លាំងក្លាយមួយឱ្យមានការអប់រំ និង ការកសាងភាពធន់បន្តទៀតនៅតាមសហគមន៍។



Photo: Nicolas Axelrod

# ធនធានសម្រាប់រៀនសូត្រ

## ក្រុមសន្សំ និង ចែកចាយគ្រាប់ពូជក្នុងសហគមន៍

លទ្ធភាពរកបានគ្រាប់ពូជមានគុណភាពជាប្រចាំ គឺជាមូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលដ្ឋានគ្រឹះទាំងឡាយសម្រាប់ការផលិតចំណីអាហារ និង មានសារសំខាន់សម្រាប់ការបង្កើត និង ការធានាសន្តិសុខស្បៀង និង ភាពធន់របស់សហគមន៍។ សៀវភៅនេះត្រូវបានចងក្រងឡើងធ្វើជាឧបករណ៍មួយសម្រាប់ការផលិត និង ការចែកចាយគ្រាប់ពូជខ្នាតតូចតាមសហគមន៍ ដោយផ្តោតសំខាន់ទៅលើការបំពេញបន្ថែមនូវការអនុវត្តសួនបន្លែ លក្ខណៈគ្រួសារ និង សួនបន្លែសហគមន៍ ដែលក្នុងនោះកសិករចង់បង្កើនប្រភេទដំណាំរបស់ខ្លួន ហើយសហគមន៍ចង់កសាងភាពធន់។ លើសពីនេះទៅទៀតសៀវភៅនេះផ្តោតគោលដៅទៅលើអង្គការមិនមែនរដ្ឋាភិបាល ឬ អង្គការសង្គមស៊ីវិលទាំងឡាយ ដែលកំពុងមានតួនាទីឈានមុខក្នុងការបង្កើត និង ការគាំទ្រដល់ក្រុមសន្សំ និង ចែកចាយគ្រាប់ពូជ។ គោលបំណងរបស់សៀវភៅនេះ គឺផ្តោតលើការធ្វើស្រូវ ឬ ការបង្កើតក្រុមសន្សំ និង ចែកចាយពូជស្រូវ ព្រោះថា រាជរដ្ឋាភិបាល និង ភ្នាក់ងារដទៃទៀតក៏បានធ្វើការងារនេះផងដែរ។

សៀវភៅនេះ ចងក្រងឡើងដោយផ្អែកលើនីតិវិធីទាំងឡាយដែលបានប្រើប្រាស់សម្រាប់ការផលិតគ្រាប់ពូជនៅឯមជ្ឈមណ្ឌលគ្រាប់ពូជរបស់បណ្តាញវត្ថុធាតុដើមសម្រាប់ការដាំដុះ (ភី.អិម.អិន) នៅ Burn's Creek រដ្ឋធានីហូនារ៉ា កោះសូឡូម៉ុង។ សៀវភៅនេះ នឹងជួយដល់លោកអ្នកឱ្យយល់ដឹងពីកត្តាទាំងអស់នេះ ហើយជួយលោកអ្នកឱ្យមានជំនាញដែលលោកអ្នកត្រូវការ ដើម្បីផលិតគ្រាប់ពូជមានគុណភាពល្អ និង ចំណីអាហារមានគុណភាពល្អ។

## ហេតុអ្វីក៏មានក្រុមសន្សំ/ចែកចាយគ្រាប់ពូជនៅក្នុងប្រទេសកម្ពុជា?

ក្នុងប្រទេសកម្ពុជា ប្រជាជនប្រហែល ៩.៥លាននាក់ ចូលរួមក្នុងការងារកសិកម្មក្នុងកម្រិតណាមួយ (អង្គការស្បៀងអាហារ និង កសិកម្ម/ក្រសួងផែនការ ឆ្នាំ២០១០) ហើយងាយប្រឈមទៅនឹងអំឡុងពេលរាំងស្ងួត និង ទឹកជំនន់ ដែលបាននឹងកំពុងកើតឡើងជាទៀងទាត់នៅក្នុងប្រទេសអស់រយៈពេលរាប់ពាន់ឆ្នាំកន្លងទៅហើយ។ ប្រទេសកម្ពុជា ក៏ត្រូវបានចាត់ទុកផងដែរថា ជាប្រទេសដែលមាន "ហានិភ័យខ្លាំងបំផុត" ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅពេលអនាគត។ មូលហេតុសំខាន់មួយ គឺលទ្ធភាពបន្សាំរបស់ប្រទេសនេះមានកម្រិតទាប មួយផ្នែកដោយសារតែការផ្តោតទៅលើ ឬ ការដាំដុះតែដំណាំស្រូវមួយមុខនៅកន្លែងណាដែលអាចដាំបាន ដោយមិនគិតពីសុខភាពដី លទ្ធភាពរកបានទឹកស្រោចស្រព និង ទម្រង់ ផ្សេងៗទៀតនៃកសិកម្មចម្រុះនោះទេ។ កត្តានេះបានធ្វើឱ្យប្រជាជនងាយរងគ្រោះប្រសិនបើធ្វើស្រូវមិនបាន ឬ កសិករមិនទទួលបានប្រាក់ចំណូលសមល្មមពីការដាំដំណាំរបស់ពួកគាត់នោះ។

*"... កសិករភាគច្រើនបំផុតដាំដុះតែដំណាំស្រូវមួយមុខ ហើយមានត្រឹមតែ ១០% ប៉ុណ្ណោះ ចញ្ចឹមត្រីដើម្បីបំពេញបន្ថែមតម្រូវការទទួលទានក្នុង គ្រួសារ។ មានកសិករត្រឹមតែ ៣% ប៉ុណ្ណោះដាំបន្លែ ហើយពួកគាត់អាចដាំបានត្រឹមតែ ៣ ទៅ ៤ ខែប៉ុណ្ណោះក្នុងមួយឆ្នាំដោយសារតែខ្វះខាតប្រព័ន្ធទឹកស្រោចស្រព..."* អង្គការអូ.ឌី.អូ.រី ដែលជាដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ។

សម្រាប់ព័ត៌មានបន្ថែម និង ដើម្បីទាញយកសៀវភៅនេះ សូមចូលទៅកាន់ ៖ http://kastomgaden.org/training/community-seed-saving/

## សួនបន្លែចម្រុះសម្របតាមអាកាសធាតុផ្តល់នូវប្រភពអាហារផ្សេងៗគ្នា និង ប្រាក់ចំណូលបន្ថែមដល់អ្នកភូមិតាមជនបទ

អង្គការដៃគូគម្រោងជេ.ស៊ី.ស៊ី.អាយ ឈ្មោះអង្គការយុវជនខ្មែរ និង ការអភិវឌ្ឍសង្គម (ខេ.វ៉ាយ.អេស.ឌី) បានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនរួមគ្នាជាមួយនឹងអាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការសហគមន៍ព្រៃឈើនិង អ្នកភូមិ ដើម្បីពង្រឹងសមត្ថភាពនៅមូលដ្ឋានក្នុងការបន្សាំទៅនឹងអាកាសធាតុដែលកំពុងប្រែប្រួល។ ជំនួយចុងក្រោយបង្អស់បាននឹងកំពុងជួយដល់គ្រួសារចំនួន ១០ (ក្នុងនោះបីគ្រួសារមានស្ត្រីជាមេគ្រួសារ) នៅក្នុងភូមិពេជ្យអន្ទង់ និង ភូមិច្រកស្រេងឯម ឱ្យបង្កើតសួនបន្លែចម្រុះសម្របតាមអាកាសធាតុ ដែលនៅទីនោះអាចដាំបន្លែ និង ដំណាំបានពេញមួយឆ្នាំ ដោយផ្តល់ឱ្យកសិករនូវប្រភពអាហារផ្សេងៗគ្នាបន្ថែមពីលើការធ្វើស្រូវតាមប្រពៃណីដែលពឹងផ្អែកទៅលើទឹកភ្លៀង កាត់បន្ថយការចំណាយទៅលើអាហារនៅលើទីផ្សារ និង បង្កើនប្រាក់ចំណូលបន្ថែម។ ស្របគ្នានេះដែរ អាជ្ញាធរឃុំបានផ្តល់ឱ្យភូមិពេជ្យអន្ទង់នូវលិខិតសរសើរមួយច្បាប់ ដោយទទួលស្គាល់ភូមិនេះថា ជាភូមិគំរូមួយសម្រាប់កិច្ចសហប្រតិបត្តិការ និង សកម្មភាពនានាពាក់ព័ន្ធនឹងការដាំព្រៃឡើងវិញ និង ការប្រែប្រួលអាកាសធាតុ។

## សូមកត់ត្រាកាលបរិច្ឆេទទាំងនេះទុក

**សហគមន៍អនុវត្តគម្រោងជេ.ស៊ី.ស៊ី.អាយ** មានគោលដៅ ៖ បម្រើជាវេទិកាអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈមួយសម្រាប់អ្នកអភិវឌ្ឍទាំងឡាយ ដែលចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ កសិកម្មមាននិរន្តរភាព និង អភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់សមត្ថភាពរបស់ពួកគាត់ ឈានទៅបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពតាមរយៈការចែករំលែកព័ត៌មានដល់គ្នាទៅវិញទៅមក។

- **អភិបាលកិច្ចមូលដ្ឋាន** ៖ សន្និសីទបណ្តាភាគីនេះនឹងផ្តោតសំខាន់ទៅលើឧបករណ៍ធ្វើការវិភាគទូទៅ ដើម្បីឱ្យមានអភិបាលកិច្ចមូលដ្ឋានកាន់តែល្អប្រសើរ នៅក្នុងបរិបទអាកាសធាតុដែលកំពុងតែប្រែប្រួល។

  *សូមទាក់ទងទៅលោក ស៊ឹម សម្បត្តិ នៅអង្គការខេដ*

- **ការគ្រប់គ្រងធនធានធម្មជាតិ និង កសិកម្មមាននិរន្តរភាព** ៖ សន្និសីទបណ្តាភាគីនេះ នឹងផ្តោតទៅលើការផ្លាស់ប្តូរចំណេះដឹងបច្ចេកទេស និង បទពិសោធន៍ផ្សេងៗពាក់ព័ន្ធនឹងកសិកម្មមាននិរន្តរភាពនៅក្នុងបរិបទអាកាសធាតុ ដែលកំពុងប្រែប្រួល។

  *សូមទាក់ទងទៅលោកស្រី ឈីន ថាវី នៅអង្គការខេដ*

**ការពន្យល់អំពីសៀវភៅសិក្សានៃគម្រោងជេ.ស៊ី.ស៊ី.អាយ** ៖ ពិនិត្យមើលលម្អិតទៅលើសៀវភៅសិក្សាគម្រោងជេ.ស៊ី.ស៊ី.អាយ រចនាសម្ព័ន្ធ ខ្លឹមសារ និង របៀបប្រើប្រាស់ និង សម្របសម្រួលឧបករណ៍នានាដែលបានដាក់បញ្ចូល។

*កាលបរិច្ឆេទ* ៖ ថ្ងៃទី ២៩-៣០ ខែឧសភា ឆ្នាំ២០១៣
*ទំនាក់ទំនង* ៖ លោកស្រី សេង សុទ្ធីរ៉ា នៅអង្គការហ្វ៊ែម ស៊ីដ

[ទិវាបរិស្ថានពិភពលោកឆ្នាំ ២០១៣]

*ប្រធានបទ ៖* គិត - ទទួលទាន - សន្សំ
*កាលបរិច្ឆេទ ៖ ថ្ងៃទី ៥ ខែមិថុនា*
*ទំនាក់ទំនងនៅកម្ពុជា ៖* ឈ្មោះ អ៊ុង សឿន (UNG Soeun) នៅ អិន.ជី.អូ ហ្វ៊ែម

**កិច្ចប្រជុំសមាជិកទូទៅនៃបណ្តាញស៊ី.ស៊ី.ស៊ី.អ៊ិន** នឹងផ្តោតទៅលើការពិភាក្សាអំពីសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រសម្រាប់បណ្តាញនេះ។

*កាលបរិច្ឆេទ* ៖ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៣
*ទំនាក់ទំនង* ៖ លោក ស៊ូ សុជាតិ នៅបណ្តាញស៊ី.ស៊ី.ស៊ី.អ៊ិន

***ប្រសិនបើលោកអ្នកចង់ចូលរួមចំណែកនៅក្នុងព្រឹត្តិបត្រព័ត៌មាននៃគម្រោងជេ.ស៊ី.ស៊ី.អាយបន្តបន្ទាប់ទៀត សូមបញ្ជាក់ពីអង្គការរបស់អ្នកពាក់ព័ន្ធនឹងសកម្មភាពការងារផ្នែកការប្រែប្រួលអាកាសធាតុ ឬ ផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍អាកាសធាតុសំខាន់ៗ ដោយផ្ញើមកកាន់ Johannes Nilsson ឱ្យបានមុនថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣។***

*គម្រោងគំនិតផ្តួចផ្តើមរួមអំពីអាកាសធាតុ (ជេ.ស៊ី.ស៊ី.អាយ) ត្រូវបានបង្កើត និង អនុវត្តដោយអង្គការខេដ ជំនួយព្រះហារដាណឺម៉ាក/ជំនួយគ្រីះបរិស័ទ (ឌី.ស៊ី.អេ/ស៊ី.អេ) និង អង្គការហ្វ៊ែមស៊ីដ ចាប់តាំងពីឆ្នាំ២០១០មក ហើយបច្ចុប្បន្ននេះបានឈានដល់ដំណាក់កាលទី ៣ របស់ខ្លួនហើយ។ គោលដៅរួមរបស់គម្រោងជេ.ស៊ី.ស៊ី.អាយ គឺធ្វើការកសាងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និង សហគមន៍ទាំងឡាយដែលគម្រោងនេះធ្វើការជាមួយ ដើម្បីបង្កើត និង អនុវត្តអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីការងាររបស់ពួកគេ។*

**គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាពី ៖**
ទស្សនៈ និង មតិយោបល់ទាំងឡាយដែលបានលើកឡើងនៅក្នុងគម្រោងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ប្រទេសស៊ុយអែតឡើយ។
SWEDEN